# *សិលាចារឹកថ្មបីដុំ (ភ្នំត្បែង) (ភាគ១)*

*ថ្មបីដុំ គឺជាទីតាំងមួយដែលស្ថិតនៅលើភ្នំត្បែង ត្រង់ភូមិក្ដី ឃុំរអាង ស្រុកសង្គមថ្មី ខេត្តព្រះវិហារ ដែលជាបូជនីយដ្ឋានព្រហ្មញ្ញសាសនា មានអាយុកាលជាងមួយពាន់ឆ្នាំ។ ការដែលគេហៅទីនេះថា "ថ្មបីដុំ" ដោយសារគេហៅទៅតាមឈ្មោះថ្មធំៗចំនួន ៣ ដុំតម្រៀបគ្នា មានសណ្ឋានដូចជាមុំចង្ក្រាន ហើយអ្នកស្រុកខ្លះហៅថា "ថ្មហោះថ្មហើរ" ដូច្នេះក៏មាន។ យោងតាមអត្ថបទរបស់លោក លឹម វណ្ណច័ន្ទ ចុះផ្សាយក្នុងគេហទំព័រ* AMS Khmer Civilization *កាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ ក្រោមចំណងជើងថា "**វត្តរអាងថ្មបីដុំ**" រៀបរាប់ថា នៅក្នុងបរិវេណវត្តថ្មបីដុំ មានសិលាចារឹកចំនួន ២ ផ្ទាំង តែលោកមិនបានបកប្រែខ្លឹមសារលម្អិតឡើយ។ សូមបញ្ជាក់ថា នៅតំបន់ថ្មបីដុំ មានសិលាចារឹកសរុបចំនួន ៤ ផ្ទាំង ដែលបានចុះបញ្ជីដោយសាលាបារាំងចុងបូព៌ាប្រទេសចំនួន ៣ ផ្ទាំង* (K.1500, K.1501, K.1502) *និង ១ ផ្ទាំងទៀត គេមិនទាន់ចុះបញ្ជីនៅឡើយ។ ម្ល៉ោះហើយ នៅក្នុងអត្ថបទភាគ១នេះ យើងនឹងលើកយកសិលាចារឹកផ្ទាំងទី១ មានលេខបញ្ជី* K.1500 *មកសិក្សាជាមុនសិន។ តើសិលាចារឹកថ្មបីដុំ* K.1500 *មានខ្លឹមសារ និងអត្ថន័យយ៉ាងដូចម្ដេចខ្លះ?*

*អត្ថបទសិលាចារឹកផ្ទាំងទី១* (K.1500) *នេះ មានចម្ងាយប្រមាណ ៣០ម៉ែត្រ ពីផ្ទាំងថ្មធំៗទាំងបីដុំដូចរៀបរាប់ខាងលើ ពោល គឺចារឹកអក្សរនៅលើផ្ទាំងថ្មដា ដែលជាកន្ទេងទីជម្រកចំពោះពួកឫឞី (ឥសី) ទាំងឡាយ ហើយសព្វថ្ងៃអ្នកស្រុកហៅថា "**ល្អាងព្រះខែ**"។ សិលាចារឹកនេះ សរសេរជាភាសាសំស្ក្រឹត និងភាសាខ្មែរ មានចំនួន ២ បន្ទាត់ (សំណេរភាសាខ្មែរនៅខាងចុងបញ្ចប់ "**វ្រះ ឥន្ទ្រគុហា**") ហើយបើពិនិត្យមើលទៅតាមរូបរាងនិងទម្រង់អក្សរ គឺអាចមានអាយុកាលស្ថិតនៅសម័យអង្គរ រវាងស.វ.ទី៩ - ១០។ ខ្លឹមសារនៃអក្សរចារឹកនេះបានបញ្ជាក់ថា ទីតាំងល្អាងព្រះខែនេះ មានឈ្មោះដើមថា "**ឥន្ទ្រគុហា**" ព្រមទាំងបានបញ្ជាក់ដល់មុខងាររបស់រូងគុហានេះថា ជាទីជម្រកអាស្រ័យរបស់ពួកឫឞី (ឥសី) ទាំងឡាយ ដែលមានបំណងប្រាថ្នាប្រតិបត្តិតបៈជាន់ខ្ពស់។ ជាទូទៅ នៅក្នុងសាសនាហិណ្ឌូ ដើម្បីទទួលបាននូវពុទ្ធិវិទ្យា ឥសីទាំងឡាយចាំបាច់ត្រូវតែប្រតិបត្តិតបៈ និងយោគៈ ដែលជាកិច្ចប្រតិបត្តិដើម្បីឱ្យប្រសើរ និងឈានទៅរកការរំដោះខ្លួនពីសេចក្ដីទុក្ខ ដែលគេហៅថា "**មោក្ស**" ។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*

ក្នុងអត្ថបទចារឹកនេះ គេប្រើប្រាស់ឃ្លាជាភាសាសំស្ក្រឹតថា “**ជយតីន្ទ្រគុហាគាឍ គុហាន្តៃកឝិលាតតី**” ដែលមានន័យថា ជ័យជម្នះរមែងកើតមានដល់រូងឥន្ទ្រគុហា ឬឥន្ទ្រគុហា។ បន្ថែមពីនេះ ខ្លឹមសារអក្សរចារឹកក៏បញ្ជាក់ឱ្យដឹងថា នៅខាងក្នុងគុហានេះ មានដុំថ្ម ឬផ្ទាំងសិលាចំនួន ១ ផ្ទាំងថែមទៀតផង។ គួរចាប់អារម្មណ៍ អ្នកនិពន្ធសិលាចារឹក បានប្រើពាក្យថា “**អាជិន្ស្យា**” ដើម្បីបញ្ជាក់បន្ថែមលើឃ្លាថា “**ឯកឝិលាតតី**” (ដី) ដែលបង្ហាញឱ្យឃើញថា ផ្ទាំងសិលាមួយដុំនោះជា “អាជិន្ស្យា” ពោល គឺមានន័យពីរយ៉ាង ជាទីអាស្រ័យប្រកបដោយជ័យជម្នះ ឬប្រកបដោយសិរីមង្គលដែលសំដៅដល់ទីកន្លែង ដែលសំដៅដល់ទីកន្លែងគួរជាទីពឹងពំនាក់ ឬគួរជាទីអាស្រ័យនៃពួកឥសីដែលប្រព្រឹត្តធម៌ស្វែងរកការរំដោះខ្លួន។ ន័យមួយទៀត “**អាជិន្ស្យា**” **(អ-ជិន)** សំដៅដល់ជាទីកន្លែងដែលមិនអាចផ្ចាញ់បាន ឬគ្មាននរណាម្នាក់អាចយកឈ្នះបាន ពោល គឺបង្ហាញឱ្យឃើញថា ទីតាំងនេះ ជាកន្លែងដ៏រឹងមាំ ចិរកាល និងគ្មានអ្វីអាចបំផ្លាញបាន។ និយាយដោយខ្លីពាក្យថា “**ជន្ម-ជន្យ**” សំដៅលើជីវិតដែលប្រកបដោយការកើត ចាស់ ឈឺ ស្លាប់ ដែលជាផលកើតចេញពីផលកម្ម។ ចំណែកឯ “**ឧទយ-អចិនាមិ**” សំដៅដល់អ្នកដែលមានបំណង ឬសេចក្ដីប្រាថ្នាឱ្យបានប្រសើរ ឬការរះខ្ពស់ត្រដែត ដែលជាការស្វែងរកការរំដោះខ្លួនឱ្យរួចផុតចាកទុក្ខពីកំណើតដោយអាស្រ័យទីស្ងប់ស្ងាត់ (ទីពិសិដ្ឋ) មានដូចជា គូន្យាគារ ឬគូន្យគ្ឫហ (ផ្ទះស្ងាត់) គុហា ឬភ្នំ។

## អត្ថបទចារឹក

១. ជយតីន្ទ្រគុហាគាឍ គុហាន្តៃកឝិលាតតី

២. បុមិណាន្ទ្ធនមាជិន្ស្យា ជន្មជន្យោទយាចិណាមិ។

ព្រះឥន្ទ្រគុហា

## សេចក្ដីប្រែ

(បន្ទាត់ទី១-២) ព្រះឥន្ទ្រគុហា រមែងមានជ័យជម្នះ ដុំថ្មមួយផ្ទាំងក្នុងរូងគុហា ជាទីជម្រកនិងទីស្នាក់អាស្រ័យដ៏ពិតប្រកបដោយសិរីមង្គល នៃឫឞី(ឥសី)ទាំងឡាយ ដែលជាអ្នកមានសេចក្ដីប្រាថ្នា ដើម្បីការធ្វើឱ្យប្រសើរឡើង ឬការរំដោះខ្លួន (មោក្ស)។ “ព្រះឥន្ទ្រគុហា”។

សរុបជារួមមក សិលាចារឹកថ្មបីដុំ ផ្ទាំងទី១ (K.1500) បានផ្ដល់ព័ត៌មានយ៉ាងសំខាន់អំពីប្រវត្តិសាស្ត្រ និងជំនឿសាសនានៅលើភ្នំត្បែង។ ខ្លឹមសារនៃសិលាចារឹកនេះមិនត្រឹមតែបញ្ជាក់ពី

អត្ថបទដោយ៖ កំ វណ្ណារ៉ា

*ឈ្មោះដើមនៃទីតាំងថាជា "**ឥន្ទ្រគុហា**" ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីតួនាទីរបស់គុហានេះ ជាសព្វញ្ញូដ្ឋាន ឬជាអាស្រមដ៏ស្ងប់ស្ងាត់សម្រាប់ពួកឥសីប្រព្រឹត្តធម៌ ប្រតិបត្តិតបៈ និងយោគៈ ដើម្បីស្វែងរកការរំដោះខ្លួន (មោក្ស) នៅក្នុងសម័យអង្គរ (ស.វ.ទី៩-១០)។ ការសិក្សាលើសិលាចារឹក K.1500 នេះ បានរួមចំណែកក្នុងការផ្តល់ព័ត៌មានយ៉ាងសំខាន់សម្រាប់ការយល់ដឹងបន្ថែមអំពីបូជនីយដ្ឋានព្រហ្មញ្ញសាសនានៅតំបន់ភ្នំត្បែង មុននឹងទីនេះក្លាយជាបូជនីយដ្ឋានព្រះពុទ្ធសាសនាថេរវាទនាសម័យទំនើប។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា*



រូបលេខ១៖ ទីតាំងថ្មបីដុំ (ភ្នំត្បែង) ថតពីលើអាកាស (ប្រភពរូប៖ ព្រះតេជគុណ សំ សោភ័ណ)



រូបលេខ២៖ ទីតាំងថ្មបីដុំ (ភ្នំត្បែង) (ប្រភពរូប៖ លឹម វណ្ណច័ន្ទ)

អត្ថបទដោយ៖ កំ វណ្ណាក៉



រូបលេខ៣៖ ទីតាំងសិលាចារឹកថ្មបីដុំ (ភ្នំត្បែង) ផ្ទាំងទី១ K.1500 (ប្រភពរូប៖ លឹម វណ្ណច័ន្ទ)



រូបលេខ៤៖ សំណៅផ្តិតសិលាចារឹកថ្មបីដុំ (ភ្នំត្បែង) ផ្ទាំងទី១ K.1500 (ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អត្ថបទដោយ៖ កំ វណ្ណារ៉ា